ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខ:៧៣៩០....អ.យ.ត

# លិខិតបញ្ជូន

## គោរពជូន:

លោក ឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
នៃក្រសួងមហាផ្ទៃ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១. | -ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ: ៤២៣...អ.យ.ត ចុះថ្ងៃទី.០៩. ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ | ០១ច្បាប់ | "មេត្តាជួយចាត់ការតាមនីតិវិធី" |
| | សរុប | ០១ច្បាប់ | |

ថ្ងៃ សុក្រ ០១រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០២២

តំណាងអយ្យការ

ឌឿ ឡុងឌី
ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

លេខៈ...៨១១...អ.យ.ត

# <u>ដីកាបង្គាប់ឲ្យចាប់ខ្លួន</u>

## យើង សឿ ឡេងឌី តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា២៧, មាត្រា ១៩៦, មាត្រា ៤៩៦ និងមាត្រា ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអម សាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ពាក្យស្នើសុំចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់មេធាវី តូច សុខា អត្តលេខ ១៣០៣ ជាមេធាវីតំណាងឲ្យ អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(ម.ព.ស.ក) នៅអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខៈ ៣៧៤២ "ឈ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូង រាជធានីភ្នំពេញ។

-**បានឃើញ** សាលដីកាលេខៈ ១១៥ "ក្រ.រ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ភ្នំពេញ។

-**បានឃើញ** សាលដីកាលេខៈ ៣៨០ "II" ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តុលាការកំពូល ។

**១-បង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតៈ**

-នាមត្រកូល-នាមខ្លួន **សំប៊ុន យ៉ានី** ភេទស្រី អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ អាស័យដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៦១ ផ្លូវលេខ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ **សំប៊ុន គឹមសួរ** (សប) ម្ដាយឈ្មោះ **ឈន មុត** (ស) ប្ដីឈ្មោះ ង៉ោ ចាន់វ៉ាង "ស" មានកូន០៣នាក់ ជានីតិជន ។

-តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ៣៧៤២ "ឈ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលា ដំបូងរាជធានីភ្នំពេញ សម្រេចផ្ដន្ទាទោសឈ្មោះ សំប៊ុន យ៉ានី ភេទស្រី កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០១(មួយ)ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរធម្មតាទាំងស្រុង ពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ១១៩A ផ្លូវលេខ៥៦៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩២ និង មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណាចសាលដីកាលេខៈ ១១៥ "ក្រ.រ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ <u>**សម្រេច**</u> តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧៤២ "ឈ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូង រាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ ដែលផ្ដន្ទាទោសលើជនជាប់ចោទ ដាក់ពន្ធនាគារកំណត់ រយៈពេល ០១(មួយ)ឆ្នាំ ត្រូវកែប្រែទៅជា ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ពីបទៈ **រំលោភលើទំនុកចិត្តពិសេស** តាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩៣ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណាចសាលដីកាលេខៈ ៣៨០ "អ" ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តុលាការកំពូល **វិនិច្ឆ័យសេចក្តី** តម្កល់សាលដីកាព្រហ្មទណ្ឌលេខៈ ១១៥ "ក្រអ រ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

ក-បង្គាប់ឲ្យស្រាវជ្រាវស្វែងរក និងចាប់ខ្លួនបុគ្គលដែលមានអត្តសញ្ញាណដូចខាងលើនេះ មកប្រគល់ឲ្យ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ខ-បង្គាប់មកមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ច ឲ្យអនុវត្តដីកាចាប់ខ្លួននេះឲ្យបានសម្រេច។

ក្រោយពេលចាប់ខ្លួនបាន មន្ត្រីនគរបាលត្រូវនាំខ្លួនទណ្ឌិត ទៅបង្ហាញខ្លួនក្នុងរយៈពេលខ្លីបំផុតនៅចំពោះ មុខលោកព្រះរាជអាជ្ញា និងនាំបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។

២-បង្គាប់ឲ្យប្រធានមណ្ឌលអប់រំកែប្រែទី២ "ម២" ឃុំខ្លួនទណ្ឌិតដែលមានអត្តសញ្ញាណដូចខាងលើតាម ដីកាបង្គាប់នេះ ។

ថ្ងៃ...សុក្រ ១១រោច ខែផល្គុន...ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី...២៥...ខែ...៣...ឆ្នាំ ២០២២

**តំណាងអយ្យការ**

សៀ ឡុងឌី

ព្រះរាជអាជ្ញារង